ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ១១ កើត ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២១*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន

## ស្តីពីជំនួបសម្តែងការគួរសមរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Jacques PELLET ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា

នៅរសៀលថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២១, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួប និងពិភាក្សាការងារជាមួយ ឯកឧត្តម Jacques PELLET ក្នុងដែលខណៈឯកឧត្តមទើបបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពថ្មី នៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងជំនួបនោះ ក៏មានវត្តមានពីមន្ត្រីការទូត និងតំណាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ប្រចាំនៅកម្ពុជា ចូលរួមផងដែរ ។

ជាមួយនឹងការស្វាគមន៍យ៉ាងកក់ក្តៅ និងអបអរសាទរចំពោះ **ឯកឧត្តម Jacques PELLET** ដែលទទួលបានការតែងតាំងជាឯកអគ្គរដ្ឋទូតថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានរំលឹកពីទំនាក់ទំនងទ្វេភាគី មិត្តភាពជិតស្និទ្ធ រវាងបារាំង និងកម្ពុជា ដែលមានតាំងពីយូរលុងណាស់មកហើយ ។ បារាំងបានដើរតួនាទីយ៉ាងសំខាន់សម្របសម្រួល ក្នុងកិច្ចដំណើរសន្តិភាពនៅកម្ពុជា ដោយឈានដល់សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ជាដើម ។ សាធារណរដ្ឋបារាំង ក៏បានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ដល់សេដ្ឋកិច្ច-សង្គមកម្ពុជា ស្ទើរគ្រប់វិស័យ ជាពិសេស ក្នុងវិស័យសុខាភិបាល ទឹកស្អាត អគ្គិសនី កសិកម្ម អប់រំ និងគម្រោងវិនិយោគសាធារណៈជាច្រើន ។ ជាក់ស្តែង, នៅក្នុងឆ្នាំ ២០២១ នេះ, បារាំង-កម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចំនួនពីរ មានទឹកប្រាក់សរុបប្រមាណ ២០,៣០ លានអឺរ៉ូ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម ទឹក និងការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ ។

ឯកឧត្តមឯកអគ្គរដ្ឋទូត Jacques PELLET បានសម្តែងនូវការអរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី និងបានលើកឡើងថា ជាការពិត កម្ពុជា និងបារាំង មានទំនាក់ទំនងយូរអង្វែងមកហើយ ពិសេស កិច្ចសហការប្រតិបត្តិការអភិវឌ្ឍន៍ជាមួយ AFD ។ កិច្ចសហប្រតិបត្តិការនេះគឺបានចូលរួមចំណែកដ៏សំខាន់ក្នុងប្រតិបត្តិការនៃមហិច្ឆតាអភិវឌ្ឍន៍របស់ប្រធាននាធិបតីបារាំង Emmanuel Macron ដែលបានការប្តេជ្ញា សម្រេចគោលដៅក្នុងការបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ ODA របស់ខ្លួនឱ្យបាន ០,៥៥% នៃផ.ស.ស នៅឆ្នាំ ២០២២ ដើម្បីចូលរួមអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ រួមមាន កម្ពុជា ផងដែរ ។ រដ្ឋាភិបាលបារាំង, តាមរយៈ AFD,

សន្យាថានឹងបង្កើនទំហំឥណទានសម្បទាន និងខិតខំជួយគៀរគហិរញ្ញប្បទានឥតសំណងពីសហគមអឺរ៉ុប និងពីប្រភពផ្សេងទៀតសម្រាប់រួមចំណែកអភិវឌ្ឍ និងស្តារសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីវិបត្តិកូវីដ-១៩ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា ។

ជាទិសដៅទៅមុខ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនថា កម្ពុជានឹងដាក់ចេញនូវ **"យុទ្ធសាស្ត្រស្តីពីការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩"** ដែលជាឯកសារបង្ហាញផ្លូវដើម្បីកម្ពុជាចាកចេញពីវិបត្តិនៃជម្ងឺកូវីដ-១៩ ឆ្ពោះទៅរកមាគ៌ានៃកំណើន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឡើងវិញប្រកបដោយសុវត្ថិភាព ចីរភាព និងបរិយាប័ន្ន ។ **"ឯកសារបង្ហាញផ្លូវ"** គឺជាក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាតាមគន្លងប្រក្រតីភាពថ្មី ក្នុងទិសដៅលើកកម្ពស់ចីរភាព កំណើន និងការកសាងភាពរឹងមាំនៃសង្គម-សេដ្ឋកិច្ចកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និងប្រជាជនបារាំងជាថ្មីម្តងទៀត ដែលបាន និងបន្តគាំទ្រ ទាំងជំនាញបច្ចេកទេស និងទាំងហិរញ្ញវត្ថុ ក៏ដូចជាបានផ្តល់នូវកិច្ចសហប្រតិបត្តិការល្អប្រសើររវាងកម្ពុជា-បារាំង នាពេលកន្លងទៅ ហើយបានស្នើឱ្យបារាំងបន្តជួយសម្របសម្រួលទាក់ទាញអ្នកវិនិយោគគិនបារាំង និងអឺរ៉ុប មកវិនិយោគនៅកម្ពុជាឱ្យបានច្រើនបន្ថែមទៀត ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** សូមជូនពរឯកឧត្តម Jacques PELLET និងសហការី ព្រមទាំងតំណាង AFD ប្រចាំនៅកម្ពុជា ទទួលបានជោគជ័យ ក្នុងការបំពេញភារកិច្ចថ្មីនៅកម្ពុជា ។